មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦

## ម.ស.ម.ក ធ្វើសន្និសីទសារព័ត៌មានដើម្បីផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវ ដែលមានចំណងជើងថា «ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជន ក្នុងព្រះរាជាណាចក្រកម្ពុជា»

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ម.ស.ម.ក នឹងធ្វើសន្និសីទសារព័ត៌មាននៅវេលា**ម៉ោង ៨:៣០ នាទីព្រឹក ថ្ងៃពុធ ទី២១ ខែកញ្ញា ឆ្នាំ ២០១៦ នៅការិយាល័យ ម.ស.ម.ក** ដើម្បីផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវថ្មីមួយដែលមានចំណងជើងថា «ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» («របាយការណ៍»)។

របាយការណ៍នេះផ្អែកទៅលើបេកគំហើញនៃការចុះទៅស្រាវជ្រាវផ្ទាល់របស់ ម.ស.ម.ក ដែលប្រមូលបានតាមរយៈការស្ទង់មតិពីមនុស្សចំនួន ១៣៥នាក់ ក្នុងខែមេសា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ ការស្ទង់មតិនេះបានសាកសួរលើអ្នកប្តូរភេទអំពីបទពិសោធន៍ និងការយល់ឃើញរបស់ពួកគេជុំវិញការរើសអើងផ្អែកលើអត្តសញ្ញាណអ្នកប្តូរភេទ ឬ ការបង្ហាញទំនោរភេទរបស់ពួកគេ ដែលការរើសអើងនេះអាចប្រព្រឹត្តដោយតួអង្គរដ្ឋ (ដូចជានគរបាល អាជ្ញាធរមូលដ្ឋាន និងតាមសាលារៀន) និងតួអង្គមិនមែនរដ្ឋ (ដូចជា គ្រួសារ កន្លែងការងារ និងតួអង្គក្នុងទំនាក់ទំនងផ្សេងៗទៀត)។ របាយការណ៍នេះក៏ធ្វើការវិភាគក្នុងបរិបទច្បាប់ សង្គម និងវប្បធម៌នៅក្នុងដំណើរជីវិតរបស់អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាផងដែរ។

ការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាទទួលរងការរើសអើងយ៉ាងខ្លាំងទៅលើផ្នែកផ្សេងៗជាច្រើនក្នុងជីវិតរស់នៅរបស់ពួកគេ។ អ្នកប្តូរភេទជាស្ត្រីស្ទើរតែទាំងអស់ដែល ម.ស.ម.ក បានស្ទង់មតិ ធ្លាប់ទទួលរងការយាយីមួយចំនួននៅទីសាធារណៈដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ ដោយក្នុងករណីជាច្រើនមានអ្នកទទួលរងការគំរាមច្រើនដងនៅក្នុងរយៈពេល១២ខែកន្លងមកនេះ។ ចំនួនអ្នកឆ្លើយតបដែលធ្លាប់ទទួលរងការបំពានដោយពាក្យសម្តី អំពើហិង្សាលើរាងកាយ រំលោភបំពានផ្លូវភេទ និងរំលោភសេពសន្ថវៈ ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ខ្លួននេះបង្ហាញថានៅតាមដងផ្លូវសាធារណៈក្នុងប្រទេសកម្ពុជាគ្មានសុវត្ថិភាពទាល់តែសោះ

សម្រាប់អ្នកប្តូរភេទជាស្រ្តី។ ការរើសអើងនៅកន្លែងការងារ គឺជាបញ្ហាធ្ងន់ធ្ងរមួយផ្សេងទៀត ដែលត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវនេះ ដោយអ្នកឆ្លើយតបជាច្រើនបានរាយការណ៍ថាខ្លួនត្រូវបានបដិសេធពីការងារ និងអ្នកជាច្រើនផ្សេងទៀតបានរាយការណ៍ថាត្រូវបានបណ្តេញចេញពីការងារ ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ។

ម.ស.ម.ក សង្ឃឹមថាការចេញផ្សាយរបាយការណ៍នេះនឹងជួយលើកកម្ពស់ការយល់ដឹងអំពីការរើសអើង និងការយាយីទៅលើអ្នកប្តូរភេទជាស្រ្តីនៅក្នុងប្រទេសកម្ពុជា ព្រមទាំងក្រើនរំឭកឱ្យទាន់ពេលវេលាដល់រដ្ឋាភិបាលកម្ពុជាថាអ្នកប្តូរភេទជាស្រ្តីជួបប្រទះការយាយី និងការរើសអើងជាបន្តបន្ទាប់ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ ហើយត្រូវតែពិចារណាក្នុងការដាក់ចេញនូវវិធានការមិនរើសអើងជាបន្ទាន់តាមរយៈការបង្កើតច្បាប់ ព្រមទាំងបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន។ ម្យ៉ាងទៀត ម.ស.ម.ក សង្ឃឹមថា ការចេញផ្សាយរបាយការណ៍ស្រាវជ្រាវនេះនឹងធ្វើឱ្យមានការបញ្ចប់ការរើសអើង និងការយាយីទៅលើអ្នកប្តូរភេទជាស្រ្តីនៅតាមទីប្រជុំជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**កម្មវិធី ៖** ការផ្សព្វផ្សាយរបាយការណ៍ និងសន្និសីទសារព័ត៌មាន
**ពេលវេលា ៖** ថ្ងៃពុធ ទី២១ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ៨:៣០ ដល់ម៉ោង ១០:៣០នាទីព្រឹក
**ទីកន្លែង ៖** ការិយាល័យ ម.ស.ម.ក ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក លោក នួន ស៊ីដារ៉ា តាមរយៈទូរសព្ទ +៨៥៥ (០) ៩៧៩ ៦៦៦ ៥៦៦ ឬតាមរយៈអ៊ីម៉ែល sidara.noun@cchrcambodia.org ឬទីប្រឹក្សាផ្នែកច្បាប់របស់ ម.ស.ម.ក លោក ផាត់ ដឺប្រ៊ូន តាមរយៈទូរសព្ទ +៨៥៥ (០) ៨៩៥៣ ៦២១៥ ឬ អ៊ីម៉ែល pat.debrun@cchrcambodia.org៕

បណ្ណាធិការៈ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម (OMCT) បណ្ដាញប្រឆាំងអំពើទារុណកម្ម អែស អូ អែស សមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្ដាញសកលនៃសេរីភាពខាងបញ្ចេញមតិ និងសម្ពន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) និងជាសមាជិកនៃសម្ពន្ធពិភពលោកដើម្បីការចូលរួមរបស់ប្រជាពលរដ្ឋ ("CIVICUS") ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងបានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីផ្លាស់ប្ដូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្ដូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី។